# អត្ថបទ

# ស្តីពី

# វិធានរដ្ឋប្បវេណី

រៀបរៀងដោយ៖ លោក ដួប មិតហេរឫទ្ធិ

បណ្ណាល័យច្បាប់-Law Library

lawlibrarysite.wordpress.com

# **ចំណោទស្រាយ**

| |
|---|
| **សំណួរទី១៖** នៅពេលមានវិវាទរដ្ឋប្បវេណី តើភាគីមានវិវាទអាចដោះស្រាយវិវាទតាមវិធានណាខ្លះ? |

## **១. សេចក្តីផ្តើម**

### **តើអ្វីទៅជាវិវាទរដ្ឋប្បវេណី?**

តាមន័យនិរុត្តិសាស្ត្រ "**វិវាទ**" មានន័យថា ជាដំណើរទាស់ទែងគ្នា ឬជាដំណើរឈ្លោះប្រកែកគ្នា។ ចំណែកឯ "រដ្ឋប្បវេណី" បានមកពីការរួមបញ្ចូលគ្នារវាងពាក្យ "រដ្ឋ" និង "បវេណី"។ **រដ្ឋ** សំដៅលើ ដែន ប្រទេស អ្នកនៅក្នុងដែន រាស្ត្រ ឬប្រជាជន រីឯ **បវេណី** គឺជាទំនៀម ពូជពង្ស តំណវង្សត្រកូល។ *ដូចនេះ វិវាទរដ្ឋប្បវេណី មានន័យថា ជាដំណើរនៃការទាស់ទែង ឬឈ្លោះប្រកែកគ្នា ទាក់ទងទៅនឹងជីវភាពរស់នៅ ទំនៀមទម្លាប់ ប្រពៃណីរបស់ប្រជាជននៅក្នុងដែនដីនៃប្រទេសណាមួយ ឬសង្គមមួយ។*

តាមន័យនីតិសាស្ត្រ វិវាទរដ្ឋប្បវេណី[1] សំដៅទៅលើវិវាទដែលកើតចេញអំពីទំនាក់ទំនងគតិយុត្តរវាងបុគ្គលឯកជនដែលមានភាពស្មើគ្នានៅក្នុងសង្គម ពាក់ព័ន្ធនឹងបញ្ហាមួយចំនួនដូចជា កម្មសិទ្ធិ និងកិច្ចសន្យា (ទំនាក់ទំនងទ្រព្យសម្បត្តិ) អាពាហ៍ពិពាហ៍ និងសន្តតិកម្ម (ទំនាក់ទំនងញាតិ)។

### **តើវិវាទរដ្ឋប្បវេណី គ្របដណ្តប់ទៅលើវិវាទអ្វីខ្លះ?**

ដូចបានដឹងរួចហើយថា ច្បាប់ទាំងឡាយអាចត្រូវបានបែងចែកជាពីរប្រភេទធំ គឺនីតិសាធារណៈ និងនីតិឯកជន ដែលទស្សនៈភាគច្រើនយល់ឃើញថា នីតិទាំងពីរនេះគួរត្រូវបានបែងចែកទៅតាមលក្ខណៈនៃទំនាក់ទំនងគតិយុត្ត។ មានន័យថា នីតិសាធាណៈ គឺជាច្បាប់ដែលបញ្ញត្តិអំពីទំនាក់ទំនងរវាងភាគីដែលគ្មានភាពស្មើគ្នា (រដ្ឋ និងពលរដ្ឋ) រីឯ នីតិឯកជនគឺជាច្បាប់ដែលបញ្ញត្តិអំពីទំនាក់ទំនងគតិយុត្តរវាងភាគីដែលមានភាពស្មើគ្នា (ពលរដ្ឋ និងពលរដ្ឋ ជាលក្ខណៈបុគ្គលឯកជន) ដូចជា ក្រមរដ្ឋប្បវេណី ក្រមពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាស ច្បាប់ស្តីពីរូបិយាណត្តិ និងប័ណ្ណសងតាមការបញ្ជា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ច្បាប់កិច្ចសន្យា និងច្បាប់ពិសេសមួយចំនួនទៀត ដូចជា ច្បាប់ស្តីពីការងារ ច្បាប់ភូមិបាល។ ដោយមូលហេតុថា ក្រមរដ្ឋប្បវេណីមានលក្ខណៈផ្សារភ្ជាប់ទៅនឹងជីវិតឯកជនរបស់ពលរដ្ឋ រវាងពលរដ្ឋ និងពលរដ្ឋ ជាពិសេសពាក់ព័ន្ធជាមួយទំនាក់ទំនងទ្រព្យសម្បត្តិ និងទំនាក់ទំនងញាតិ ដូច្នេះហើយទើបគេហៅក្រមរដ្ឋប្បវេណីថាជានីតិឯកជន។ ជាក់ស្តែង មាត្រា១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានប្រើពាក្យ "រដ្ឋប្បវេណី" ជំនួស "នីតិឯកជន" មានន័យថា ក្រមរដ្ឋប្បវេណី គឺជាច្បាប់ទូទៅនៃនីតិឯកជន។

*ដូចនេះ វិវាទរដ្ឋប្បវេណី សំដៅទៅលើវិវាទទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងទំនាក់ទំនងទ្រព្យសម្បត្តិ (កម្មសិទ្ធិ និងកិច្ចសន្យា) និងទំនាក់ទំនងញាតិ (អាពាហ៍ពិពាហ៍ និងសន្តតិកម្ម) ព្រមទាំងវិវាទដែលបានកំណត់នៅក្នុងច្បាប់ពិសេសមួយចំនួនទៀត ដូចជា វិវាទពាណិជ្ជកម្ម វិវាទការងារ វិវាទដីធ្លី។*

### **តើគេអាចដោះស្រាយវិវាទរដ្ឋប្បវេណី តាមវិធានណាខ្លះ?**

តាមក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រឹមតែបានកំណត់ពីគោលបំណងនៃបណ្តឹងរដ្ឋប្បវេណី ក្នុងការការពារសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន តាមរយៈការដោះស្រាយវិវាទដោយបង្ខំ[2] (ដោយប្រើយន្តការតាមផ្លូវតុលាការ

[1] យោងតាមខ្លឹមសារនៅក្នុងមាត្រា១នៃក្រមរដ្ឋប្បវេណី(២០០៧) និងសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី(២០១០)

[2] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២ ។

រដ្ឋប្បវេណី) តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានអនុញ្ញាតយ៉ាងជាក់លាក់ឱ្យមានការប្រើប្រាស់ប្រាស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ទោះបីជាបន្ទាប់ពីភាគីដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការរួចហើយក៏ដោយ[3]។ មានន័យថា ក្រមនីតិវិធីរដ្ឋប្បវេណី លើកទឹកចិត្តឱ្យធ្វើការចរចា និងផ្សះផ្សា។ ម៉្យាងវិញទៀត នៅក្នុងសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី (ភាគ១៖ នីតិវិធីបណ្តឹង) បានពន្យល់យ៉ាងច្បាស់ថា ក្នុងវិវាទរដ្ឋប្បវេណី ភាគីវិវាទ[4]អាចប្រើប្រាស់វិធាននៃការដោះស្រាយវិវាទដោយខ្លួនឯង[5] ដែលរួមមាន ការសះជា (ការចរចា) សន្ទានកម្ម និងមជ្ឈត្តកម្ម ឬវិធាននៃការដោះស្រាយវិវាទដោយបង្ខំ[6] (តាមប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី)។

តាមពិតទៅកម្ពុជា បានអនុម័តច្បាប់ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាដំបូងរបស់ខ្លួន ដោយការបង្កើតឡើងនូវក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅឆ្នាំ២០០១។ បន្ទាប់មក នៅឆ្នាំ២០០៦ កម្ពុជាបានអនុម័តច្បាប់ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាលើកទី២ ហៅថាច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ក្រៅពីនេះនៅមានច្បាប់ពិសេសមួយចំនួនទៀត ដែលផ្តល់លទ្ធភាពតាមផ្លូវច្បាប់ និងលើកទឹកចិត្តឱ្យមានការប្រើប្រាស់យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មុននឹងប្តឹងទៅតុលាការ តាមមធ្យោបាយនៃការចរចា សន្ទានកម្ម និងមជ្ឈត្តកម្ម ដូចជា ច្បាប់ស្តីពីការងារ (មាត្រា៣០០ដល់៣០៧) ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ (មាត្រា៤២) ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី (មាត្រា៣) អនុក្រឹត្យលេខ៤៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការសុរិយោដី (ប្រការ៧ដល់១១)។

*ដូចនេះ ផ្អែកលើបទដ្ឋានគតិយុត្តខាងលើនេះ ជាពិសេសក្រមនីតិវិធីរដ្ឋប្បវេណី គេអាចកំណត់បានយ៉ាងច្បាស់លាស់ថា នៅពេលមានវិវាទរដ្ឋប្បវេណី ភាគីវិវាទអាចដោះស្រាយវិវាទតាមវិធាន ២យ៉ាង ដូចខាងក្រោម៖*

*(១) វិធាននៃការដោះស្រាយវិវាទដោយខ្លួនឯង ឬយន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលជាវិធីដោះស្រាយវិវាទដោយស្ម័គ្រចិត្ត និងដោយឆន្ទានុសិទ្ធិរបស់ភាគី។ វិធាននេះ មាន៣ទៀត គឺ ការចរចា (ឬការសះជា) សន្ទានកម្ម និងមជ្ឈត្តកម្ម។ ឬ*

*(២) វិធាននៃការដោះស្រាយដោយបង្ខំ ឬយន្តការនៃការដោះស្រាយវិវាទតាមផ្លូវតុលាការរដ្ឋប្បវេណី ដែលជាវិធីដោះស្រាយដោយអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី។*

តើវិធាននៃការដោះស្រាយវិវាទរដ្ឋប្បវេណីទាំងពីរខាងលើនេះ មានអត្ថន័យ សារៈសំខាន់ បែបបទ និងនីតិវិធីយ៉ាងដូចម្តេច? តើភាគីវិវាទ ត្រូវជ្រើសរើសវិធានណាមួយដែលសមស្របបំផុតចំពោះវិវាទរបស់ខ្លួន? ដូច្នេះ សូមពិនិត្យមើលនៅផ្នែកបន្តបន្ទាប់ដូចខាងក្រោម។

## ២. វិធាននៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ឬហៅកាត់ថា ADR (Alternative Dispute Resolution) គឺសំដៅដល់វិធីផ្សេងៗដែលភាគីវិវាទអាចដោះស្រាយវិវាទដោយស្ម័គ្រចិត្ត និងដោយឆន្ទានុសិទ្ធិក្រៅអំពីប្រព័ន្ធជំនុំ

[3] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦ មាត្រា៩៧ "តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ" និងមាត្រា១០៤ "នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងផ្សះផ្សាជាដំបូងសិន លើកលែងតែយល់ឃើញថាមិនសមរម្យ"។

[4] រាល់ពាក្យ "វិវាទ" ដែលប្រើនៅក្នុងការបកស្រាយនេះ គឺសំដៅទៅលើវិវាទរដ្ឋប្បវេណី។

[5] វិធានដោះស្រាយវិវាទដោយខ្លួនឯង ជាវិធីដោះស្រាយដោយស្ម័គ្រចិត្ត និងដោយឆន្ទានុសិទ្ធិរបស់ភាគី ដែលត្រូវបានគេហៅថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

[6] ការដោះស្រាយវិវាទដោយបង្ខំ គឺជាដោះស្រាយវិវាទតាមផ្លូវតុលាការ។

ជម្រះដែលមានពីមុនមកដែលពឹងផ្អែកទាំងស្រុងលើតុលាការ។ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រមូលផ្តុំដោយទម្រង់ជាច្រើននៃវិធីដោះស្រាយវិវាទ ក្នុងនោះ ការចរចា សន្ធានកម្ម និងមជ្ឈត្តកម្ម គឺជាទម្រង់ទូទៅបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

## ២.១ ការចរចា ឬការសះជា

### ក. អត្ថន័យ និងក្របខ័ណ្ឌគតិយុត្តនៃការចរចា

ការចរចា គឺជាដំណើរការនៃការឆ្លើយឆ្លងគ្នាទៅវិញទៅមក ដែលតាមរយៈនេះ ភាគីទាំងអស់ដាក់ជូន ឬពិចារណាលើសំណើផ្សេងៗ រហូតដល់សំណើណាមួយត្រូវបានធ្វើឡើង ហើយត្រូវបានគេទទួលយក។ ការចរចាអាចដោះស្រាយវិវាទតូច និងធំ ហើយអាចជាដំណើរការដ៏សាមញ្ញ ឬស្មុគស្មាញបំផុតដែរ។ មនុស្សធ្វើការចរចានៅគ្រប់ពេលវេលាទាំងអស់ ព្រោះវាគឺជាទម្រង់សំខាន់បំផុតនៃការប្រាស្រ័យទាក់ទងរវាងមនុស្ស និងមនុស្ស។ មនុស្សធ្វើការចរចាទោះបីជានៅពេលគ្មានវិវាទក៏ដោយ។ ជាក់ស្តែង មនុស្សអាចចរចាគ្នាអំពីតម្លៃផ្លែក្រូច តម្លៃសាច់ជ្រូក ឬតម្លៃលក់ម៉ូតូ ជាដើម។

ការចរចាអាចធ្វើឡើងតាមវិធីជាច្រើនយ៉ាង ដូចជា ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់រវាងភាគីវិវាទ ឬតាមរយៈតំណាងរបស់ភាគីទាំងនោះ។ ការចរចាអាចធ្វើឡើងតាមបែបធម្មតា ឬមានលក្ខណៈផ្លូវការ។ នៅក្នុងប្រទេសកម្ពុជា ការចរចាច្រើនតែធ្វើឡើងនៅចំពោះមុខគ្នាផ្ទាល់ ប៉ុន្តែគេក៏អាចចរចាតាមរយៈទូរស័ព្ទ សំបុត្រ ឬសារអេឡិចត្រូនិចផងដែរ។ នៅពេលដែលមានការចរចាពាក់ព័ន្ធនឹងវិវាទតាមផ្លូវច្បាប់ ការចរចាអាចនឹងរួមផ្សំទៅដោយមធ្យោបាយទំនាក់ទំនងទាំងអស់នេះ។

ច្បាប់នៅក្នុងប្រទេសកម្ពុជាគាំទ្រឱ្យមានការចរចា។ ក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាលើកទឹកចិត្តឱ្យមានការសម្រុះសម្រួលគ្នាតាមការចរចារវាងភាគីវិវាទ។ ជាក់ស្តែង មាត្រា៩៧ នៃក្រមនេះបានសរសេរថា "តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ" និងមាត្រា១០៤ "នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បង ផ្សះផ្សាជាដំបូងសិនលើកលែងតែយល់ឃើញថាមិនសមរម្យ"។ នេះជាក្របខ័ណ្ឌគតិយុត្ត ដែលបង្ហាញពីការទទួលស្គាល់វិធីដោះស្រាយវិវាទតាមរយៈការចរចា ជាផ្លូវការច្បាប់តែម្តង។

### ខ. សារៈប្រយោជន៍ ឬភាពចាំបាច់នៃការចរចា

បច្ចុប្បន្នមានយុត្តាធិការជាច្រើនផ្តល់ភាពអនុគ្រោះដល់ដំណោះស្រាយវិវាទតាមរយៈការចរចា ដោយសារតែមានហេតុផលល្អពីការប្រើប្រាស់មធ្យោបាយនៃការចរចា។ ដោយហេតុថា យុត្តាធិការជាច្រើនមានបញ្ជីរឿងក្តីជាច្រើនដែលមិនទាន់វិនិច្ឆ័យ ដូច្នេះមានវិធីតែម៉្យាងគត់ក្នុងការដោះស្រាយវិវាទឱ្យទាន់ពេល គឺលើកទឹកចិត្តភាគីវិវាទឱ្យពិភាក្សាអំពីបញ្ហាវិវាទជាមួយគ្នា ហើយព្យាយាមឈានទៅរកការព្រមព្រៀងគ្នាមួយ។ តួយ៉ាងដូចជានៅសហរដ្ឋអាមេរិក ៩០%នៃរឿងក្តីត្រូវបានដោះស្រាយក្រៅប្រព័ន្ធតុលាការ[7] ហើយការចរចាគឺជាទម្រង់ដែលមានប្រជាប្រិយភាពបំផុត។ នៅប្រទេសកម្ពុជា ការអង្កេតលើក្រុមហ៊ុនតូចៗមួយចំនួនដែលធ្វើឡើងដោយ

---

[7] Susan Patterson and Grant Seabolt, *សារធាតុសំខាន់ៗនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ*, ទំព័រទី៥, បោះពុម្ពលើកទី២ ឆ្នាំ២០០១ ។

ធនាគារពិភពលោក បានរកឃើញថា ការចរចាគឺជាវិធីសាស្ត្រដែលមានការនិយមច្រើនជាងគេបំផុតក្នុងការដោះស្រាយវិវាទ (មានរហូតដល់ទៅ៩២%)[8]។

សំខាន់ជាងនេះទៅទៀត ការចរចាផ្ដល់នូវការសន្សំសំចៃ រក្សាភាពឯកជន បង្កើនភាពបត់បែន និងរក្សាទំនាក់ទំនងជាបន្តបានល្អជាងការដោះស្រាយវិវាទតាមសន្ទានកម្ម មជ្ឈត្តកម្ម និងតុលាការ។

**គ. បែបបទ និងនីតិវិធីនៃការចរចា**

ក្រៅពីការហាមឃាត់ចំពោះការបំភ័ន្ត ឬបង្ខិតបង្ខំ ដំណើរការចរចាមិនមានប្រើវិធានអ្វីឱ្យជាក់លាក់នោះទេ ពីព្រោះមិនមានច្បាប់ ឬលក្ខន្តិកៈណាមួយដែលណែនាំអំពីដំណើរការចរចាឡើយ។ ប៉ុន្តែ គេអាចស្វែងយល់អំពីដំណើរការនៃការចរចា បានកាន់តែល្អប្រសើរឡើង តាមរយៈដំណាក់កាលចំនួន៥ ដូចខាងក្រោម៖

**(១) ដំណាក់កាលត្រៀម៖** នៅក្នុងដំណាក់កាលនេះ ភាគី និងមេធាវីរបស់ខ្លួនត្រូវពិនិត្យមើលរឿងក្ដីយ៉ាងប្រុងប្រយ័ត្ន ហើយព្យាយាមធ្វើសេចក្ដីសន្និដ្ឋានជាមូលដ្ឋានមួយចំនួនមុននឹងចាប់ផ្ដើមចរចា តាមរយៈការស្វែងរកអង្គហេតុ (ដូចជា ការសម្ភាស ពិនិត្យភស្តុតាងជាឯកសារ កិច្ចសន្យា ឬវិក្កយប័ត្រផ្សេងៗ) ការវិភាគច្បាប់ដោយផ្អែកលើអង្គហេតុ ការស្វែងយល់អំពីផលប្រយោជន៍ និងគោលដៅរបស់ភាគីវិវាទ ការបង្កើតជម្រើសល្អបំផុតដែលអាចរកបានក្រៅពីដំណោះស្រាយតាមការចរចា ហៅកាត់ថា BATNA (the Best Available Alternative to a Negotiated Settlement) ការពិចារណាលើការទាមទាររបស់ភាគីដទៃ និងជំហានចុងក្រោយនៃដំណាក់កាលត្រៀម គឺការបង្កើតយុទ្ធសាស្ត្រសម្រាប់ការចរចា។

**(២) ដំណាក់កាលផ្ដើម៖** ជាញឹកញាប់ដំណាក់កាលផ្ដើមនៃការចរចាតែងត្រូវបានបំភ្លេចចោលដោយចាត់ទុកថាវាមិនសំខាន់។ ផ្ទុយទៅវិញ ដំណាក់កាលនេះមានភាពចាំបាច់ចំពោះភាពជោគជ័យនាពេលក្រោយមកទៀត។ នៅក្នុងដំណាក់កាលនេះ ភាគីវិវាទ និង/ឬមេធាវី ធ្វើទំនាក់ទំនាក់ជាមួយគ្នាទៅវិញទៅមក ដើម្បីពិភាក្សាអំពីបែបបទនៃការចរចា ដូចជា *តើគួរមានការចរចាដែរ ឬទេ* (ភាគីស្នើការចរចាអាចត្រូវបានគេមើលឃើញថាជាការបង្ហាញភាពទន់ខ្សោយរបស់ខ្លួន) និង *តើការចរចាត្រូវធ្វើឡើងនៅពេលណា* (អាចចង្អុលបង្ហាញកម្រិតមួយនៃតម្រូវការ ឬសេចក្ដីអស់សង្ឃឹម) *នៅកន្លែងណា* (ដើម្បីរកទីតាំងដែលមានប្រៀប) និង *ដោយរបៀបណា* (ដើម្បីកំណត់ពីមធ្យោបាយនៃការចរចា ដោយផ្ទាល់ ឬតាមរយៈសារអេឡិចត្រូនិច ឬតាមទូរស័ព្ទ)។

**(៣) ដំណាក់កាលព័ត៌មាន៖** នៅក្នុងដំណាក់កាលនេះ ភាគីទាំងពីរចាប់ផ្ដើមផ្ដល់ព័ត៌មានដល់គ្នាទៅវិញទៅមក។ ភាគីនីមួយៗរៀបរាប់ ឬពិភាក្សាអំពីអង្គហេតុ និងអង្គច្បាប់ ហើយបន្ទាប់មកផ្ដល់នូវសំណើដើម្បីដោះស្រាយឱ្យគ្នាទៅវិញទៅមក។ ការដែលភាគីចរចាព្រមព្រៀងគ្នាទុកចន្លោះពេលចរចាជាញឹកញាប់ ក៏ជាប្រការដែលមានអត្ថប្រយោជន៍ផងដែរ ដើម្បីដកថយមកធ្វើការពិចារណាលើព័ត៌មានទាំងអស់ដែលពួកគេស្វែងយល់ពីគ្នាទៅវិញទៅមក ហើយដែលអាចនឹងមានការផ្លាស់ប្ដូរ BATNA និងយុទ្ធសាស្ត្រនៃការចរចាឡើងវិញ។ ការចរចាត្រូវព្យាយាមប្រើប្រាស់ប្រយោគវិជ្ជមាន ជំនួសឱ្យការគំរាមកំហែង ឬពាក្យពេចន៍ដែលមានភាពអវិជ្ជមាន។ ការព្យាយាមធ្វើឱ្យភាគីម្ខាងទៀតបន្តការនិយាយនៅក្នុងអំឡុងពេលចរចា គឺជាប្រការដ៏មានសារៈប្រយោជន៍។ ប្រសិនបើភាគីម្ខាងនោះនិយាយកាន់តែច្រើន គាត់អាចបញ្ចេញព័ត៌មានកាន់តែបានច្រើន។ អ្នកចរចាដែលពូកែតែងតែព្យាយាមស្ដាប់យ៉ាងសកម្មបំផុតនៅក្នុងដំណាក់កាលនេះ។ យ៉ាងណាមិញ ព័ត៌មាន

---

[8] ធនាគារពិភពលោក, *ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តនៃប្រទេសកម្ពុជា៖ ការវាស់ស្ទង់អភិបាលកិច្ចសេដ្ឋកិច្ច និងគោលនយោបាយបទប្បញ្ញត្តិ*, ទំព័រទី៤៨, ឆ្នាំ២០០៧ ។

ដែលមិនមែនជាពាក្យសម្ដី (ដូចជា ឥរិយាបថ ទឹកមុខ កាយវិការ) ក៏មានច្រើនដែរ ដែលអ្នកចរចាអាចរកបានដើម្បីវាយតម្លៃពីភាគីម្ខាងទៀត។

(៤) **ដំណាក់កាលបែងចែក ឬផ្អែកលើផលប្រយោជន៍៖** នេះគឺជាដំណាក់កាលដែលភាគីទាំងពីរស្វែងរក *ដំណោះស្រាយផ្អែកលើផលប្រយោជន៍* (ឈ្នះ-ឈ្នះ) ដែលអាចមានជាមុនសិន ហើយប្រសិនបើមិនមានលទ្ធភាពណាមួយនោះទេ ទើបបន្តទៅរក*ដំណោះស្រាយបែបបែងចែក* ទៀត (ឈ្នះ-ចាញ់)។ ដំណោះស្រាយទាំងពីរនេះមានវិធីសាស្ត្រលម្អិតរបស់វា ប៉ុន្តែចំណុចដែលគួរចងចាំ គឺគេត្រូវផ្ដាច់មនុស្សចេញពីបញ្ហា ផ្ដោតលើផលប្រយោជន៍មិនមែនលើជំហរ បង្កើតជម្រើសសម្រាប់ផលចំណេញរួម និងសង្កត់ធ្ងន់លើការប្រើប្រាស់លក្ខណៈវិនិច្ឆ័យមិនលម្អៀង។

(៥) **ដំណាក់កាលបញ្ចប់៖** ជាដំណាក់កាលចុងក្រោយ ដែលត្រូវកត់ត្រាជាលាយលក្ខណ៍អក្សរនូវរាល់លក្ខខណ្ឌ ដែលបានព្រមព្រៀងគ្នាក្នុងអំឡុងពេលនៃការចរចា ហើយត្រូវចុះហត្ថលេខាលើកំណត់ត្រានោះ។ បន្ទាប់មក ត្រូវសរសេរលក្ខខណ្ឌស្ថាពរឱ្យបានឆាប់ ជៀសវាងមានការប្ដូរចិត្តរបស់ភាគី និងទាមទារចរចាឡើងវិញ។ ករណីដែលគ្មានការព្រមព្រៀង ដំណើរការចរចាត្រូវបញ្ចប់ ហើយភាគីអាចបន្តដោះស្រាយតាមវិធីផ្សេង។

## ២.២ សន្ធានកម្ម

### ក. អត្ថន័យ និងក្របខ័ណ្ឌគតិយុត្តនៃសន្ធានកម្ម

សន្ធានកម្ម អាចត្រូវបានផ្ដល់និយមន័យយ៉ាងទូលំទូលាយថា ជាការចរចាដែលមានជំនួយ ឬការជួយសម្របសម្រួល។ ជាទូទៅសន្ធានកម្មត្រូវមានភាគីវិវាទពីរ ឬច្រើន ដែលព្យាយាមចរចាលើដំណោះស្រាយមួយដោយមានជំនួយពីភាគីទីបី គឺសន្ធានការីដែលមានអព្យាក្រឹត្យភាពចំពោះភាគីទាំងនោះ ក៏ដូចជាលទ្ធផលនៃដំណោះស្រាយនោះផ្ទាល់។ សន្ធានការី មិនមានសិទ្ធិអំណាចក្នុងការចាប់បង្ខំឱ្យយកដំណោះស្រាយណាមួយឡើយ។ ផ្ទុយទៅវិញភាគីវិវាទនៅតែមានសិទ្ធិអំណាចក្នុងការសម្រេចថាតើខ្លួនចង់ ឬមិនចង់ដោះស្រាយ។ ប្រសិនបើភាគីវិវាទមិនចង់ដោះស្រាយ ឬមិនមានការព្រមព្រៀងគ្នា នោះនឹងគ្មានដំណោះស្រាយឡើយ ទោះជាមានការខិតខំប្រឹងប្រែងរបស់សន្ធានការីយ៉ាងណាក៏ដោយ។ មិនដូចក្នុងមជ្ឈត្តកម្ម ឬបណ្ដឹងទៅតុលាការឡើយ សន្ធានការីគ្រាន់តែអាចស្នើឡើងនូវដំណោះស្រាយចំពោះភាគីតែប៉ុណ្ណោះ។

នៅក្នុងប្រទេសកម្ពុជា សន្ធានកម្មតែងតែដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គម ហើយបានក្លាយជាវិធីសាស្ត្រដ៏ពេញនិយមជាងគេក្នុងដំណោះស្រាយវិវាទ បន្ទាប់ពីការចរចា[9]។ ជាក់ស្ដែងក្របខ័ណ្ឌគតិយុត្តមួយចំនួនរបស់កម្ពុជាបានអនុញ្ញាតជាផ្លូវការឱ្យមានការប្រើប្រាស់សន្ធានកម្មក្នុងការដោះស្រាយវិវាទ ដូចជា ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ មាត្រា៤២ បានបើកលទ្ធភាពឱ្យមានការផ្សះផ្សាគ្នាលើបញ្ហាលែងលះចំនួន ១៥ថ្ងៃនៅថ្នាក់ឃុំសង្កាត់មុននឹងបញ្ជូនរឿងក្ដីទៅតុលាការ។ ច្បាប់ស្ដីពីការងារ មាត្រា៣០០មាត្រា៣០១ និងមាត្រា៣០៣ បានតម្រូវឱ្យក្រសួងការងារជួយសម្រុះសម្រួលវិវាទការងាររវាងនយោជក និងនយោជិត មុននឹងប្ដឹងទៅតុលាការ។ ប្រសិនបើមានវិវាទដីធ្លី ភាគីអាចស្នើសុំសន្ធានកម្មពីគណៈកម្មការសុរិយោដី ឬអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី[10]។ វិវាទតូចតាចមួយចំនួន ដូចជា បញ្ហាបំណុល កិច្ចសន្យា ព្រំប្រទល់ដី កសិដ្ឋាន ការបរិហារកេរ្តិ៍ និងអំពើហិង្សាដែលមិនបង្ករបួសស្នាម អាចត្រូវបានសម្រុះសម្រួលជាផ្លូវការនៅត្រឹមកម្រិត

[9] ធនាគារពិភពលោក, *ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តនៃប្រទេសកម្ពុជា*, ទំព័រ៤០, ឆ្នាំ២០០៧

[10] អនុក្រឹត្យលេខ៤៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការសុរិយោដី ប្រការ៧-១១ (ឆ្នាំ២០០២) និងព្រះរាជក្រឹត្យស្ដីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មាត្រា៣ (ឆ្នាំ២០០៦)។

ក្រុមប្រឹក្សាឃុំ/សង្កាត់នៅក្នុងមូលដ្ឋានតាមរយៈកម្មវិធីមជ្ឈមណ្ឌលសេវាយុត្តិធម៌[11]។ ចៅក្រមកម្ពុជា ក៏ត្រូវបានប្រគល់សិទ្ធិអំណាចដើម្បីសម្រុះសម្រួលរវាងភាគីនៃបណ្តឹងផងដែរ[12]។

**ខ. សារៈប្រយោជន៍ ឬភាពចាំបាច់នៃសន្ធានកម្ម**

សន្ធានកម្មអាចជួយដោះស្រាយបញ្ហាមួយចំនួនពាក់ព័ន្ធនឹងប្រព័ន្ធយុត្តធម៌នៅកម្ពុជា។ ការសិក្សាមួយចំនួនបង្ហាញថា សន្ធានកម្មអាចកែលម្អការទទួលបានយុត្តិធម៌តាមវិធីច្រើនយ៉ាង។ សន្ធានកម្មអាច***ជួយឱ្យស្រទាប់ប្រជាពលរដ្ឋក្រីក្រ*** នៅក្នុងសង្គមបានចូលរួមនៅក្នុងដំណោះស្រាយវិវាទ ក្នុងករណីដែលពួកគេមិនអាចមានលទ្ធភាពជួលមេធាវីសម្រាប់បណ្តឹងទៅតុលាការ។ សន្ធានកម្មអាចធ្វើឡើងនៅទីជនបទ ឬតំបន់ដែលមិនមានតុលាការ។ សន្ធានកម្មអាចធ្វើឡើងនៅចុងសប្តាហ៍ ឬនៅពេលល្ងាចដើម្បីផ្តល់លទ្ធភាពឱ្យភាគីវិវាទ អ្នកតំណាង ឬអ្នកពាក់ព័ន្ធអាចចូលរួមបាន ជាពិសេសមិនខកខានសម្រាប់ការងារធ្វើស្រែចំការរបស់ភាគីជាប្រជាកសិករ។ លក្ខណៈក្រៅផ្លូវការនៃសន្ធានកម្មក៏អាចកាត់បន្ថយនូវការគំរាមកំហែងចំពោះប្រជាជន ដោយជំនួសមកវិញនូវសុវត្ថិភាពល្អជាងវិធានតុលាការ ដែលប្រជាជនមានភាពសង្ស័យ និងភ័យខ្លាច។

សន្ធានកម្មក៏អាចកែលម្អឥរិយាបថរបស់ប្រជាពលរដ្ឋចំពោះប្រព័ន្ធតុលាការកម្ពុជាផងដែរ។ ការសង្កត់ធ្ងន់នៃសន្ធានកម្មទៅលើការសម្រេចចិត្តដែលផ្តោតលើភាគី អនុញ្ញាតឱ្យភាគីដោះស្រាយរឿងក្តីស្របតាមផលប្រយោជន៍របស់ពួកគាត់។ ដោយសារតែដំណោះស្រាយត្រូវបានធ្វើឡើង***ដោយស្ម័គ្រចិត្ត*** សន្ធានកម្មលុបបំបាត់នូវលក្ខណៈចាប់បង្ខំដែលតម្រូវដោយសាលក្រមតុលាការ។ នៅពេលខាងមុខ សន្ធានកម្មក៏អាចជួយ***ពង្រឹងលទ្ធិប្រជាធិបតេយ្យ*** នៅកម្ពុជាផងដែរ។ នៅក្នុងប្រទេសជាច្រើន សន្ធានកម្មមានតួនាទីរៀបចំមេដឹកនាំសហគមន៍ បង្កើននូវការចូលរួមពីសំណាក់ប្រជាពលរដ្ឋ និងបង្កើតដំណើរការជាសាធារណៈដែលជួយសម្រួលដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធ និងការផ្លាស់ប្តូរជាវិជ្ជមានរបស់សង្គម ដែលសុទ្ធសឹងតែជាអត្ថប្រយោជន៍។ លើសពីនេះទៅទៀត ការប្រើប្រាស់សន្ធានកម្មកាន់តែច្រើនឡើង អាច***ជួយកសាង និងពង្រឹងវប្បធម៌ស្រុះស្រួលគ្នា*** នៅកម្ពុជា ដោយកាត់បន្ថយនូវជម្លោះ និងការប្រឈមមុខដាក់គ្នា ជំនួសមកវិញដោយការចាប់ផ្តើមមានការទទួលខុសត្រូវផ្ទាល់ខ្លួនដើម្បីដោះស្រាយជម្លោះទាំងនោះ។

**គ. បែបបទ និងនីតិវិធីនៃសន្ធានកម្ម**

នៅក្នុងដំណើរការសន្ធានកម្ម ត្រូវបានកំណត់ជាទូទៅចំនួន៧ ដំណាក់កាល ដូចខាងក្រោម៖

**(១) ការផ្តួចផ្តើមសន្ធានកម្ម៖** សន្ធានកម្មអាចកើតឡើងក្នុងកាលៈទេសៈមួយក្នុងចំណោម៣ ដូចតទៅ (i) ភាគីមាន ខស្តីពីដំណោះស្រាយវិវាទនៅក្នុងកិច្ចសន្យា ដែលមានស្រាប់របស់ពួកគេដែលបានជ្រើសរើសយកមធ្យោបាយសន្ធានកម្មមកប្រើ (ii) ភាគីសម្រេចចិត្តធ្វើសន្ធានកម្មបន្ទាប់ពីវិវាទបានកើតឡើង ឬ (iii) តុលាការបានបង្គាប់ ឬណែនាំឱ្យភាគីធ្វើសន្ធានកម្ម។ នៅក្នុងកាលៈទេសៈទី (i) និង (ii) ភាគីដែលផ្តួចផ្តើមសន្ធានកម្មផ្ញើលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀតដើម្បីសម្រុះសម្រួលវិវាទនោះ។ ភាគីម្ខាងទៀតអាចយល់ព្រមតាមការអញ្ជើញ ឬបដិសេធ។ ប្រសិនបើភាគីម្ខាងទៀតយល់ព្រម នោះភាគីទាំងពីរត្រូវចាប់ផ្តើមកំណត់វិធាន និងស្វែងរកសន្ធានការី។ ប្រសិនបើភាគីម្ខាងទៀតបដិសេធ សន្ធានកម្មនឹងមិនកើតមានឡើយ ហើយភាគីអាចអនុវត្តវិធានផ្សេងទៀត។ ករណីនេះ ប្រសិនបើភាគីមានខស្តីពីសន្ធានកម្មនៅក្នុងកិច្ចសន្យា នោះ

[11] ប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ លេខ៤៨៥ ប្រការ៣និង៤ (ឆ្នាំ២០០៦)។

[12] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៧ និងមាត្រា១០៤ (ឆ្នាំ២០០៦)។

ភាគីអាចស្វែងរកសេចក្តីបង្គាប់ពីតុលាការដែលតម្រូវភាគីម្ខាងទៀត*ចូលរួមធ្វើសន្ធានកម្ម* ប៉ុន្តែសេចក្តីបង្គាប់នេះមិនអាចបង្គាប់ឱ្យភាគីម្ខាងទៀតនោះត្រូវតែ*យល់ព្រមដោះស្រាយ* នៅក្នុងសន្ធានកម្មនោះឡើយ។

ប្រសិនបើតុលាការបង្គាប់ឱ្យមានសន្ធានកម្ម (ក្នុងកាលៈទេសៈទី (iii)) ដែលពាក់ព័ន្ធនឹងកម្មវិធីចំណុះឱ្យស្ថាប័នតុលាការ នោះតុលាការទំនងជានឹងផ្តល់ដល់ភាគីនូវសន្ធានការី និងវិធានអនុវត្តផងដែរ។

**(២) ការជ្រើសរើសសន្ធានការី៖** បន្ទាប់ពីសន្ធានកម្មត្រូវបានបង្កើតឡើង ភាគីវិវាទត្រូវជ្រើសរើសសន្ធានការី និងតាមរបៀបណាមួយដែលខ្លួនពេញចិត្ត។ ប្រសិនបើភាគយល់ព្រមប្រើប្រាស់មជ្ឈមណ្ឌលសន្ធានកម្មណាមួយជាក់លាក់ នោះសន្ធានការី និងរបៀបជ្រើសរើសនឹងត្រូវកំណត់តាមវិធាននៃមជ្ឈមណ្ឌលនោះ។

**(៣) ការផ្តល់ព័ត៌មានដល់សន្ធានការី៖** ភាគីត្រូវផ្តល់ព័ត៌មានដល់សន្ធានការីអំពីរឿងរ៉ាវវិវាទ ហើយសន្ធានការីត្រូវរក្សាទុកព័ត៌មាននេះជាការសម្ងាត់។ ចំពោះករណីដែលរឹតតែស្មុគស្មាញ សន្ធានការីអាចស្នើឱ្យភាគីផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរដែលពន្យល់អំពីអង្គហេតុ (អង្គហេតុនៃការព្រមព្រៀង និងអង្គហេតុនៃវិវាទ) ច្បាប់ដែលអាចអនុវត្តបាន និងភស្តុតាងជាឯកសារដទៃទៀតដែលគាំទ្រដល់ភាគីនីមួយៗ។ សន្ធានការីក៏អាចចង់ដឹងអំពីសាក្សីដែលត្រៀមខ្លួនធ្វើសក្ខីកម្មឱ្យភាគីនីមួយៗ ហើយក៏អាចស្នើសុំឱ្យភាគីនីមួយៗបង្ហាញពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន ក៏ដូចជាការសាកល្បងពីមុនមកក្នុងការដោះស្រាយវិវាទនោះ។ ព័ត៌មានទាំងអស់នេះនឹងជួយឱ្យសន្ធានការីដឹកនាំកិច្ចប្រជុំសម្រុះសម្រួលកាន់តែមានប្រសិទ្ធភាព។

**(៤) ការបើកកិច្ចប្រជុំសម្រុះស្រួល៖** នៅពេលបើកកិច្ចប្រជុំ ភាគីវិវាទត្រូវជួបជាមួយសន្ធានការីដោយផ្ទាល់ និងដោយព្រមគ្នាទាំងពីរភាគី (ករណីស្មុគស្មាញអាចមានវត្តមានមេធាវីរបស់ភាគីចូលរួមដែរ)។ កិច្ចប្រជុំ នឹងប្រព្រឹត្តទៅដោយណែនាំអ្នកចូលរួមឱ្យស្គាល់គ្នា ពិភាក្សា និងពិនិត្យមើលឡើងវិញនូវដំណើរការសន្ធានកម្ម កំណត់អំពីវិធានដែលត្រូវអនុវត្តតាម ផ្តល់ពេលវេលាឱ្យភាគីនីមួយៗរៀបរាប់អំពីវិវាទ និងជំហរអង្គច្បាប់ និងអង្គហេតុរបស់ពួកគេ ផ្លាស់ប្តូរព័ត៌មានសំខាន់ៗទៅវិញទៅមករវាងភាគីវិវាទ ផ្តល់ដល់ភាគីនូវឱកាសបង្ហាញពីអារម្មណ៍ និងផលប្រយោជន៍របស់ខ្លួន និងចុងក្រោយកំណត់ផ្នែកដំបូងនៃការព្រមព្រៀង និងមិនព្រមព្រៀង។

**(៥) កិច្ចប្រជុំដោះស្រាយបញ្ហាទូទៅ៖** នេះជាពេលដែលសន្ធានការី និងភាគីវិវាទព្យាយាមស្វែងរកដំណោះស្រាយ។ នៅចំណុចនេះជាទូទៅ សន្ធានការីព្យាយាមបំភ្លឺផ្នែកដែលមានការព្រមព្រៀង និងមិនមានការព្រមព្រៀង។ ក្នុងការដោះស្រាយបញ្ហាទូទៅនេះ សន្ធានការីប្រើជំនាញរបស់ខ្លួនបី គឺការស្តាប់ ការបកស្រាយឡើងវិញ និងការបង្កើតជម្រើសជូនភាគីវិវាទ តាមរយៈការកំណត់ឱ្យបាននូវផលប្រយោជន៍ និងបញ្ហា បង្កើតជាមួយភាគីនូវរបៀបវារៈក្នុងការដោះស្រាយផលប្រយោជន៍ និងបញ្ហានោះ ពិភាក្សាជាក្រុម ឬ/និងជាឯកជនអំពីបញ្ហានីមួយៗ និងធ្វើសេចក្តីព្រាងកិច្ចព្រមព្រៀងដោះស្រាយ។

**(៦) ការប្រជុំជាឯកជន៖** ច្រើនធ្វើឡើងក្នុងករណីដែលសន្ធានកម្មនៅនឹងថ្កល់ មិនអាចដោះស្រាយបញ្ហាតាមការពិភាក្សាជាក្រុម។ ជំនួបជាឯកជនអនុញ្ញាតឱ្យភាគីចែករំលែកព័ត៌មានឯកជនជាមួយសន្ធានការី ព្រោះពួកគេអាចមានភាពមិនស្រួលក្នុងចិត្តដើម្បីចែករំលែកនៅចំពោះមុខភាគីម្ខាងទៀត។ ម្យ៉ាងទៀតកិច្ចប្រជុំបែបនេះអនុញ្ញាតឱ្យសន្ធានការីទទួលបាននូវជំនឿទុកចិត្តកាន់តែខ្លាំងពីអ្នកចូលរួម/ភាគី។ សន្ធានការីអាចបង្ហាញនូវការយល់ចិត្តកាន់តែច្រើនចំពោះភាគីនៅក្នុងអំឡុងពេលប្រជុំជាឯកជន ដែលប្រហែលជាគាត់មិនអាចធ្វើបែបនេះបានឡើយនៅក្នុងសម័យប្រជុំជាក្រុម ដោយខ្លាចថាខ្លួននឹងមានកាយវិការលម្អៀង។ បរិយាកាសឯកជនក៏អនុញ្ញាតឱ្យសន្ធានការីមានលទ្ធភាពទម្លាក់ជំហររបស់ភាគីកាន់តែខ្លាំង និងបង្ខំពួកគេឱ្យពិចារណាយ៉ាងហ្មត់ចត់នូវអ្វីដែលភាគីម្ខាងទៀតបានស្នើឡើង ហើយសន្ធានការីក៏អាចស្នើឡើងនូវដំណោះស្រាយចាំបាច់នានាបានដែរ។

**(៧) ការបញ្ចប់សន្ទានកម្ម៖** សន្ទានកម្មអាចនឹងបញ្ចប់ដោយ (i) ភាគីបានឈានដល់ការព្រមព្រៀងគ្នាទាំងស្រុង ឬ(ii) ភាគីមិនបានឈានដល់ការព្រមព្រៀងគ្នាទាំងស្រុងទេ ប៉ុន្តែនឹងបន្តសន្ទានកម្មនៅពេលក្រោយ ឬ (iii) ភាគីបានឈានទៅដល់ស្ថានភាពជាប់គាំង ហើយសន្ទានកម្មត្រូវបានបញ្ចប់។ ចំពោះលទ្ធផលទី (i) សន្ទានការីត្រូវព្រាងកិច្ចព្រមព្រៀងឱ្យបានឆាប់រហ័សដើម្បីដាក់ជូនភាគីវិវាទចុះហត្ថលេខា ជៀសវាងការពន្យាពេលដែលអាចនឹងនាំឱ្យភាគីផ្លាស់ប្តូរការសម្រេចចិត្តដោយសារភាគីទទួលរងនូវសម្ពាធផ្សេងៗ។ ចំពោះលទ្ធផលទី (ii) សន្ទានការីត្រូវសង្កត់ធ្ងន់លើការរីកចម្រើនដែលបានបង្កើតឡើង និងលើកឡើងនូវសំណើមួយចំនួនសម្រាប់ការពិចារណាក្នុងកិច្ចប្រជុំលើកក្រោយ ហើយគួរកំណត់ពេលវេលានៃការប្រជុំនោះឱ្យបានឆាប់។ ចំពោះលទ្ធផលទី (iii) សន្ទានការីមិនអាចធ្វើអ្វីបានទាំងអស់ រីឯភាគីមានសេរីភាពក្នុងការបន្តវិវាទរបស់ពួកគេនៅក្នុងវេទិកាផ្សេងទៀត ដូចជា មជ្ឈត្តកម្ម ឬបណ្តឹងទៅតុលាការ។

## ២.៣ មជ្ឈត្តកម្ម

### ក. អត្ថន័យ និងក្របខ័ណ្ឌគតិយុត្តនៃមជ្ឈត្តកម្ម

មជ្ឈត្តកម្ម គឺជាវិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការចម្បងទីបី។ នៅក្នុងមជ្ឈត្តកម្ម គូភាគីដាក់វិវាទរបស់ខ្លួនជូនទៅភាគីទីបីដែលអព្យាក្រឹត្យ (ដែលជាទូទៅហៅថា "មជ្ឈត្តករ" ឬ "ក្រុមមជ្ឈត្តករ" សម្រាប់ភាគីទីបីដែលមានច្រើននាក់)។ ភាគីទីបីនេះពិចារណាអំពីភស្តុតាងដែលភាគីវិវាទបានដាក់ជូន និងចេញសេចក្តីសម្រេចមួយហៅថា "មជ្ឈត្តវិនិច្ឆ័យ"។ មជ្ឈត្តវិនិច្ឆ័យ ជាទូទៅគឺមានភ្ជាប់កាតព្វកិច្ចចំពោះគូភាគីទាំងអស់ យ៉ាងណាមិញក្នុងករណីខ្លះ មជ្ឈត្តវិនិច្ឆ័យក៏អាចមិនភ្ជាប់កាតព្វកិច្ចចំពោះគូភាគីដែរ។

មជ្ឈត្តកម្មភាគច្រើនផ្តោតទៅលើដំណោះស្រាយវិវាទផ្នែកពាណិជ្ជកម្ម ដូចជា តុលាការមជ្ឈត្តការអន្តរជាតិ (ICC) របស់សភាពាណិជ្ជកម្មអន្តរជាតិទីក្រុងប៉ារីស សមាគមមជ្ឈត្តការអាមេរិកទីក្រុងញូវយ៉ក តុលាការមជ្ឈត្តការអន្តរជាតិទីក្រុងឡុងដ៍ គណៈកម្មការមជ្ឈត្តការផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិប្រទេសចិន មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិសិង្ហបូរី និងមានវេទិកាមជ្ឈត្តកម្មផ្សេងៗទៀត នៅប្រទេសជប៉ុន ថៃ ម៉ាឡេស៊ី តៃវ៉ាន់ ហុងកុង ឥណ្ឌា និងឥណ្ឌូនេស៊ី។ ក្រៅពីវិវាទផ្នែកពាណិជ្ជកម្ម មជ្ឈត្តកម្មក៏ត្រូវបានបង្កើតឡើងសម្រាប់ដោះស្រាយវិវាទផ្នែកការងារ និងកីឡាផងដែរ (តុលាការមជ្ឈត្តការសម្រាប់វិស័យកីឡា)។

សម្រាប់កម្ពុជា ក្របខ័ណ្ឌគតិយុត្តដែលបង្កើតឱ្យមានមជ្ឈត្តកម្មមាន ច្បាប់ស្តីពីការបង្កើតក្រុមប្រឹក្សាអាជ្ញាកណ្តាល (បង្កើតឡើងនៅឆ្នាំ២០០១ សម្រាប់ដោះស្រាយវិវាទផ្នែកការងារ) និងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (បង្កើតឡើងនៅឆ្នាំ២០០៦ សម្រាប់ដោះស្រាយវិវាទផ្នែកពាណិជ្ជកម្ម)។

### ខ. សារៈប្រយោជន៍ ឬភាពចាំបាច់នៃមជ្ឈត្តកម្ម

មជ្ឈត្តកម្មភាគច្រើនប្រើសម្រាប់ដោះស្រាយវិវាទផ្នែកពាណិជ្ជកម្ម ដែលទាមទារឱ្យមានលក្ខណៈផ្លូវការជាងវិធានចរចា និងសន្ទានកម្ម។ មិនតែប៉ុណ្ណោះ មជ្ឈត្តវិនិច្ឆ័យអាចមានលក្ខណៈភ្ជាប់កាតព្វកិច្ច និងមិនភ្ជាប់កាតព្វកិច្ច ដែលផ្តល់នូវភាពទន់ភ្លន់ជាជម្រើសសម្រាប់ភាគីវិវាទ។ លើសពីនេះទៅទៀត ការដោះស្រាយតាមវិធានមជ្ឈត្តកម្មមានភាពលឿនរហ័ស និងចំណាយតិចជាងវិធានតាមផ្លូវតុលាការ។

### គ. បែបបទ និងនីតិវិធីនៃមជ្ឈត្តកម្ម

ផ្ទុយពីការដោះស្រាយវិវាទតាមការចរចា និងសន្ទានកម្មដែលគ្មានវិធានណាមួយជាក់លាក់ក្នុងការកំណត់អំពីបែបបទ និងនីតិវិធីនៃការដោះស្រាយឱ្យបានច្បាស់លាស់ មជ្ឈត្តកម្មគឺជាវិធានមួយដែលមានដំណើរការជាក់

លាក់ចំនួន៦ដំណាក់កាល ដូចដែលបានកំណត់នៅក្នុងច្បាប់ថ្មីស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់កម្ពុជា ដែលច្បាប់នេះយកលំនាំភាគច្រើនពីច្បាប់គម្រូរបស់ UNCITRAL ស្តីពីមជ្ឈការផ្នែកពាណិជ្ជកម្មអន្តរជាតិ។ ដំណើរការមជ្ឈត្តកម្មទាំង៦ ដំណាក់កាលនោះ មានដូចខាងក្រោមៈ

(១) ការផ្តួចផ្តើមមជ្ឈត្តកម្ម

(២) ការជ្រើសរើសវេទិកាមជ្ឈត្តកម្ម

(៣) នីតិវិធីមុនសវនាការ

(៤) សវនាការមជ្ឈត្តការ

(៥) ការធ្វើសេចក្តីសម្រេចចិត្ត

(៦) ការប្តឹងឧបាស្រ័យ និងការដាក់ឱ្យអនុវត្ត។

ចំពោះដំណើរការលម្អិតនៅក្នុងដំណាក់កាលនីមួយៗ ខាងលើនេះ មានកំណត់នៅក្នុងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦។

## ៣. វិធាននៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ(ករណីតាមផ្លូវតុលាការរដ្ឋប្បវេណី)

### ក. សញ្ញាណ និងបញ្ញត្តិច្បាប់នៃការដោះស្រាយវិវាទតាមផ្លូវតុលាការរដ្ឋប្បវេណី

ទោះបីជាមានវិធាននៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដូចបានរៀបរាប់ខាងលើ ដែលរួមមានការចរចា សន្ធានកម្ម និងមជ្ឈត្តកម្ម ដែលមានលក្ខណៈសាមញ្ញ ងាយស្រួល ទន់ភ្លន់ និងលឿនរហ័សក៏ដោយក៏ប៉ុន្តែមានករណីមួយចំនួន វិវាទរវាងបុគ្គលឯកជនមិនអាចដោះស្រាយបានតាមរយៈការប្រឹងប្រែងដោយស្ម័គ្រចិត្ត និងដោយឆន្ទានុសិទ្ធិរបស់ភាគីតាមវិធានខាងលើនេះបានឡើយ។ ដូច្នេះ រដ្ឋត្រូវបង្កើតតុលាការ ហើយប្រសិនបើមានពាក្យបណ្តឹងពីភាគីម្ខាងនៃវិវាទ តុលាការត្រូវកោះហៅភាគីទាំងសងខាងដោយមិនគិតពីឆន្ទៈនៃភាគីម្ខាងទៀត ត្រូវឱ្យភាគីធ្វើការអះអាង និងត្រូវវិនិច្ឆ័យ (ឬហៅថាសេចក្តីសម្រេច) ទៅលើចំណុចថាតើអំណះអំណាងរបស់ភាគីមួយណាដែលមានភាពត្រឹមត្រូវ និងត្រូវបង្ខំឱ្យភាគីទាំងសងខាងអនុវត្តតាមសេចក្តីសម្រេចនោះ។ ការធ្វើបែបនេះ គឺតុលាការតាំងចិត្តធ្វើការដោះស្រាយវិវាទរវាងភាគីទាំងពីរដោយបង្ខំ។ ប្រព័ន្ធបែបនេះគេហៅថា ប្រព័ន្ធរឿងក្តីរដ្ឋប្បវេណី ឬប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ដែលជាការដោះស្រាយវិវាទដោយបង្ខំ ឬការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ (តាមផ្លូវតុលាការរដ្ឋប្បវេណី)។

ការដោះស្រាយវិវាទរដ្ឋប្បវេណី តាមផ្លូវតុលាការរដ្ឋប្បវេណី មានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦។

### ខ. គោលបំណងនៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី

ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ឬការដោះស្រាយវិវាទតាមផ្លូវតុលាការរដ្ឋប្បវេណី មានគោលបំណងការពារសិទ្ធិស្របច្បាប់របស់បុគ្គលឯកជនតាមរយៈការដោះស្រាយវិវាទដោយបង្ខំ។ ក្នុងគោលបំណងនេះ មាត្រា២កថាខ័ណ្ឌទី១នៃក្រមនីតិវិធីរដ្ឋប្បវេណីចែងថា បណ្តឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។ ការបង្កើតប្រព័ន្ធរដ្ឋប្បវេណីនេះឡើង គឺដើម្បីធ្វើការទទួលស្គាល់តាមរយៈតុលាការ ថាបុគ្គលម្នាក់មានសិទ្ធិស្របច្បាប់ និងដើម្បីការពារសិទ្ធិរបស់បុគ្គលនោះដោយបញ្ចប់នូវវិវាទ។ មាត្រា២ កថាខ័ណ្ឌទី២ បានកំណត់ថា ជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការ

ចំពោះវិវាទរដ្ឋប្បវេណី។ នេះជាការធានាសិទ្ធិជាមូលដ្ឋាន និងសិទ្ធិផ្សេងៗទៀតរបស់ប្រជាពលរដ្ឋតាមរយៈការពឹងពាក់ការដោះស្រាយវិវាទតាមផ្លូវតុលាការរដ្ឋប្បវេណី។

**គ. នីតិវិធីនៃការដោះស្រាយវិវាទតាមផ្លូវតុលាការរដ្ឋប្បវេណី**

ការដោះស្រាយវិវាទតាមផ្លូវតុលាការរដ្ឋប្បវេណី គឺមាននីតិវិធីច្បាស់លាស់ និងតឹងរឹងជាងវិធាននៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយមានកំណត់ជាបទដ្ឋានគតិយុត្តសម្រាប់អនុវត្តជាក់លាក់ នោះគឺក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦។ ក្រមនេះ បានកំណត់នូវនីតិវិធីនៃការជម្រះក្តី ដោយបែងចែកជា៤ ដំណាក់កាលធំៗដូចខាងក្រោមៈ

**(១) ការដាក់ពាក្យបណ្តឹងទៅតុលាការៈ** ភាគីដើមចោទត្រូវដាក់ពាក្យបណ្តឹងទៅតុលាការជាលាយលក្ខណ៍អក្សរ ដោយមានបញ្ជាក់ពីឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ព្រមទាំងកំណត់នូវកម្មវត្ថុនៃបណ្តឹងឱ្យបានច្បាស់លាស់។ បន្ទាប់មក តុលាការនឹងពិនិត្យពាក្យបណ្តឹងនោះ។ ប្រសិនបើពាក្យបណ្តឹងនោះត្រឹមត្រូវ និងបំពេញលក្ខខណ្ឌច្បាប់គ្រប់គ្រាន់ តុលាការចាត់ការបន្ត។ ផ្ទុយទៅវិញ ប្រសិនបើនៅមានចំណុចខ្វះខាត តុលាការនឹងបង្គាប់ឱ្យកែតម្រូវ ហើយប្រសិនបើភាគីបណ្តឹងមិនកែតម្រូវចំណុចខ្វះខាតនោះទេ តុលាការនឹងលើកពាក្យបណ្តឹងចោលដោយដីកាសម្រេច។ ម្យ៉ាងទៀត ប្រសិនបើពាក្យបណ្តឹងនោះខ្វះលក្ខខណ្ឌដែលកំណត់ដោយច្បាប់ ឬខុសច្បាប់តែម្តង តុលាការក៏ត្រូវលើកពាក្យបណ្តឹងនោះចោលដែរ ដោយប្រើសាលក្រម។

**(២) នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលៈ** ជាដំណាក់កាលនៃការរៀបចំនូវការអះអាងរបស់ភាគីចំណុចវិវាទនៃរឿងក្តី និងភស្តុតាងដែលពាក់ព័ន្ធនឹងចំណុចវិវាទ។ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមនេះ នូវពេលវេលាណាដែលភាគីទាំងសងខាងអាចចូលរួមបាន ដោយមិនចាំបាច់បើកជាសាធារណៈទេ ប៉ុន្តែអាចអនុញ្ញាតឱ្យមានអ្នកសង្កេតការណ៍ចូលរួម។ នៅក្នុងដំណាក់កាលនេះ សកម្មភាពរបស់ភាគីគឺការអះអាងដោយដាក់នូវមធ្យោបាយតទល់ ឬការពារខ្លួន រីឯសកម្មភាពរបស់តុលាការគឺការរៀបចំឱ្យភាគីធ្វើការអះអាង និងពិនិត្យភស្តុតាងដែលផ្តល់ដោយភាគី។ ជាមួយគ្នានេះដែរ តុលាការត្រូវសាកល្បងផ្សះផ្សាជាដំបូងសិន មុននឹងបន្តទៅនីតិវិធីបន្ទាប់ លើកលែងតែយល់ឃើញថាមិនសមរម្យ។

**(៣) ការទាញហេតុផលដោយផ្ទាល់មាត់ៈ** ជាដំណាក់កាលនៃការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និងបើកចំហជាសាធារណៈ។ សកម្មភាពនៅក្នុងដំណាក់កាលនេះ មានដូចជា ការថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ដែលជាចំណុចរួមនៃវិវាទ ការដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មី (សម្រាប់ករណីពិសេស ដូចជា ចំណុចដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់តុលាការ) ការពិនិត្យភស្តុតាងដែលរួមមានភស្តុតាងផ្ទាល់ និងប្រយោល ភស្តុតាងជាមនុស្ស និងជាវត្ថុ ភស្តុតាងស្រប និងផ្ទុយ។

**(៤) ការសម្រេចសេចក្តីៈ** ដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការធ្វើសេចក្តីសម្រេចមួយដែលមានលក្ខណៈគ្រប់គ្រាន់ទៅតាមទម្រង់ ដែលច្បាប់បានកំណត់ ហៅថា "សាលក្រម"។ សាលក្រម មានច្រើនប្រភេទ និងមានលក្ខខណ្ឌនៃការបង្កើតយ៉ាងច្បាស់លាស់ ព្រមទាំងមានអនុភាពចាប់បង្ខំឱ្យអនុវត្តយ៉ាងតឹងរឹង។ សាលក្រមត្រូវប្រកាសក្នុងរយៈពេលមួយខែ បន្ទាប់ពីការបញ្ចប់ការទាញហេតុផលផ្ទាល់មាត់លើកលែងតែករណីស្មុគស្មាញ ឬកាលៈទេសៈពិសេស ហើយការប្រកាសត្រូវធ្វើឡើងជាសាធារណៈ និងត្រូវអានសេចក្តីសម្រេចបញ្ចប់ដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ ការសម្រេចសេចក្តីរបស់តុលាការ ក៏អាចធ្វើឡើង

ដោយដីកាសម្រេចបានដែរ ដែលការចេញដីកាសម្រេចនេះអាចឆ្លងកាត់ ឬមិនឆ្លងកាត់ដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់បាន។

សម្រាប់នីតិវិធីលម្អិតនៃការជម្រះក្តីរដ្ឋប្បវេណីតាមដំណាក់កាលទាំង៤ខាងលើនេះ មានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ ក្នុងគន្ថីទី២ "នីតិវិធីនៃការជម្រះក្តីលើកទី១"។

## ៤. សន្និដ្ឋាន

តាមការបង្ហាញជូនខាងលើ យើងឃើញថា វិវាទរដ្ឋប្បវេណីអាចត្រូវបានដោះស្រាយតាមវិធាន២ ធំៗគឺ (១) វិធាននៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលជាវិធីដោះស្រាយដោយស្ម័គ្រចិត្ត និងដោយឆន្ទានុសិទ្ធិរបស់ភាគី ក្នុងនោះរួមមាន ការចរចា ឬការសះជា សន្ធានកម្ម និងមជ្ឈត្តកម្ម និង (២) វិធាននៃការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ (តាមផ្លូវតុលាការរដ្ឋប្បវេណី) ដែលជាវិធានដោះស្រាយដោយបង្ខំ។ វិធាននីមួយៗសុទ្ធតែមានចំណុចវិជ្ជមាន និងអវិជ្ជមានរបស់វា ហេតុនេះនៅពេលដែលមានវិវាទតើភាគីត្រូវជ្រើសរើសវិធានណាមួយដើម្បីដោះស្រាយឱ្យទទួលបានអត្ថប្រយោជន៍សមស្របបំផុតចំពោះខ្លួន ពីព្រោះគ្មានគំរូ ឬវិធានណាមួយដែលល្អ និងមានប្រសិទ្ធភាពគ្រប់ករណីនោះទេ។

ដូចនេះ មធ្យោបាយល្អបំផុតដែលភាគីអាចធ្វើបាននៅពេលជ្រើសរើសវិធានដើម្បីដោះស្រាយវិវាទ គឺត្រូវពិចារណាទៅលើលក្ខណៈវិនិច្ឆ័យមួយចំនួន ដូចតទៅ៖ (១) លទ្ធភាពគ្រប់គ្រងរបស់ភាគី (តើភាគីចង់បានភាពបត់បែនដើម្បីបង្កើតវិធានផ្ទាល់ខ្លួនដែរ ឬទេ?) (២) ភាពផ្លូវការ (៣) ល្បឿន (តើភាគីមានតម្រូវការបន្ទាន់ដើម្បីដោះស្រាយបញ្ហាដែរឬទេ?) (៤) ភាពជាឯកជន (តើវិវាទមានពាក់ព័ន្ធនឹងព័ត៌មានរសើបអំពីភាគីដែលអាចបណ្តាលឱ្យមានភាពអាម៉ាសនៅពេលផ្សព្វផ្សាយជាសាធារណៈដែរឬទេ?) (៥) ការចំណាយ (តើវិវាទនោះពាក់ព័ន្ធនឹងចំនួនទឹកប្រាក់ប៉ុន្មាន?) (៦) ទំនាក់ទំនងរបស់ភាគី (តើវាមានសារៈសំខាន់យ៉ាងណាដែលភាគីរក្សាទំនាក់ទំនងរបស់ពួកគេ?) (៧) តុល្យភាពនៃអំណាច (តើភាគីមានវិសមភាពអំណាចមុខងារក្នុងសង្គម ឬអំណាចសេដ្ឋកិច្ចដែរ ឬទេ?) (៨) ផលប្រយោជន៍សាធារណៈ និង(៩) ភាពយូរអង្វែង (តើភាគីចង់បានដំណោះស្រាយដែលមានលក្ខណៈយូរអង្វែង ពោលគឺការចូលជាធរមានដែរឬទេ?)។

ឈរលើលក្ខណៈវិនិច្ឆ័យខាងលើនេះ ភាគីអាចដឹងថាខ្លួនគួរជ្រើសរើសវិធានណាមួយហើយ ពីព្រោះចំពោះវិធានដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺផ្តល់លទ្ធភាពគ្រប់គ្រងសម្រាប់ភាគី ដំណើរការឆាប់រហ័ស ចំណាយតិច រក្សាភាពឯកជន និងអាចរក្សាទំនាក់ទំនងបន្តរវាងភាគី។ ចំណែកឯវិធានដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការផ្តល់នូវលក្ខណៈជាផ្លូវការ ជាសាធារណៈ ភាពយូរអង្វែង និងការការពារដ៏រឹងមាំក្នុងស្ថានភាពដែលភាគីមានអតុល្យភាពនៃអំណាច។

**សំណួរទី២៖** ចូរលើកឡើងពីគុណសម្បត្តិ និងគុណវិបត្តិនៃវិធានដោះស្រាយវិវាទរដ្ឋប្បវេណីតាមផ្លូវតុលាការរដ្ឋប្បវេណី?

មនុស្សរស់នៅក្នុងសង្គមតែងត្រូវផ្សារភ្ជាប់ជានិច្ចនូវទំនាក់ទំនងរវាងគ្នានឹងគ្នា សម្រាប់ការប្រាស្រ័យរស់នៅក្នុងជីវភាពប្រចាំថ្ងៃ។ ទំនាក់ទំនងនេះ ប្រាកដជាជៀសមិនរួចពីការអាក់អន់ចិត្ត ការខាត និងចំណេញ ការប្រតិបត្តិ ឬមិនប្រតិបត្តិតាមកិច្ចសន្យា ដែលជាមូលហេតុនៃការបង្កឱ្យមានវិវាទ ជាពិសេសវិវាទរដ្ឋប្បវេណី ដែលអាចកើតមានចំពោះបុគ្គលឯកជន ពីព្រោះនៅក្នុងសង្គមសេដ្ឋកិច្ចទីផ្សារ បុគ្គលម្នាក់ៗដែលជាសមាជិកសង្គមនោះ ចូលរួមក្នុងជីវភាពសេដ្ឋកិច្ច តាមរយៈការដោះដូរទំនិញ និងសេវា ដោយប្រើរូបិយវត្ថុជាចម្បង។ ជាធម្មតា ការដោះដូរទំនិញ និងសេវា ត្រូវបានធ្វើឡើងតាមរយៈកិច្ចសន្យា ឬការសន្យារវាងបុគ្គលម្នាក់ និងបុគ្គលម្នាក់ទៀត ហើយកិច្ចសន្យា ឬការសន្យានោះអាចនឹងត្រូវគោរព ឬមិនគោរពតាមដោយភាគីណាមួយ។ ករណីដែលមានភាគីណាមួយមិនប្រតិបត្តិតាមកិច្ចសន្យា និងមិនគោរពសិទ្ធិរបស់ភាគីម្ខាងទៀត នោះវិវាទនឹងកើតមានឡើង។ ដូច្នេះ ភាគីត្រូវដោះស្រាយវិវាទនោះដោយជ្រើសរើសយកវិធាននៃការដោះស្រាយវិវាទណាដែលផ្តល់នូវផលប្រយោជន៍ដ៏សមស្របបំផុតចំពោះខ្លួន។ វិធីដោះស្រាយមានច្រើន (ដូចជា ការចរចា សន្ធានកម្ម មជ្ឈត្តកម្ម និងតុលាការ) ប៉ុន្តែគ្មានវិធីណាមួយដែលល្អបំផុត និងមានប្រសិទ្ធភាពគ្រប់ករណី និងគ្រប់កាលៈទេសៈឡើយ។

តួយ៉ាងការដោះស្រាយវិវាទរដ្ឋប្បវេណី តាមផ្លូវតុលាការរដ្ឋប្បវេណីតែងផ្តល់នូវគុណសម្បត្តិ និងគុណវិបត្តិព្រមជាមួយគ្នា។ ដូច្នេះ តើអ្វីខ្លះជាគុណសម្បត្តិ និងគុណវិបត្តិនៃការដោះស្រាយវិវាទតាមផ្លូវតុលាការរដ្ឋប្បវេណី?

## ១. គុណសម្បត្តិ

### ក. លក្ខណៈជាផ្លូវការ

ការដោះស្រាយវិវាទតាមផ្លូវតុលាការ មានលក្ខណៈផ្លូវការ និងមានភាពប្រាកដប្រជាជាងការដោះស្រាយវិវាទតាមវិធាននៃការចរចា សន្ធានកម្ម និងមជ្ឈត្តកម្ម ពីព្រោះតុលាការអនុវត្ត និងគោរពទៅតាមនីតិវិធី និងគោលការណ៍ច្បាប់ទាំងស្រុង។ ម៉្យាងទៀត តុលាការមានយន្តការនៃការអនុវត្តសាលក្រមច្បាស់លាស់ នោះគឺស្ថាប័នអាជ្ញាសាលា។ ដូចនេះ ភាគីនៃវិវាទមិនអាចគេចវេះ មិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនចំពោះភាគីម្ខាងទៀតបានឡើយ ផ្ទុយពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលភាគីអាចមិនគោរពតាមលក្ខខណ្ឌនៃការស្រុះស្រួលគ្នា ឬមិនអនុវត្តកិច្ចព្រមព្រៀងដែលបានបង្កើតឡើងដោយភាគីទាំងពីរជាលក្ខណៈឯកជននោះ។

### ខ. លក្ខណៈជាសាធារណៈ

ដំណើរការទាញហេតុផលផ្ទាល់មាត់ ឬសវនាការ និងការប្រកាសសាលក្រម ឬដីកាសម្រេចរបស់តុលាការមានលក្ខណៈជាសាធារណៈ។ ឧទាហរណ៍ ដូចជាក្នុងស្ថានភាពខ្លះភាគីអាចការពារខ្លួនជាសាធារណៈប្រឆាំងនឹងការប្តឹងទាមទារ ឬដើម្បីដាក់ទណ្ឌកម្មភាគីម្ខាងទៀតឱ្យមានការអាម៉ាស់មុខជាសាធារណៈ។ ជាក់ស្តែងនៅក្នុងមាត្រា១១៥ កថាខ័ណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា "ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើឡើងនៅសាលសវនាការជាសាធារណៈ" ។ មូលហេតុដែលក្រមនេះ កំណត់ឱ្យធ្វើការជម្រះក្តីបែបនេះ គឺក្នុងគោលបំណងលុបបំបាត់នូវការជម្រះក្តីសម្ងាត់ដែលពុំមានយុត្តិធម៌។ ម៉្យាងទៀត ការជម្រះក្តីជាសាធារណៈអាច

ធានាបាននូវគោលការណ៍ចំពោះមុខ និងផ្តល់ឱកាសឱ្យភាគីទាំងសងខាង អាចធ្វើសេចក្តីថ្លែងការណ៍អំពីការអះអាងរបស់ពួកគេដោយយុត្តិធម៌ និងស្មើភាពគ្នា ក៏ដូចជាផ្តល់ឱកាសឱ្យភាគី អាចតវ៉ាចំពោះការអះអាងរបស់ភាគីម្ខាងទៀតដែរ។ ជាងនេះទៅទៀត ការជម្រះក្តីជាសាធារណៈ អាចធានាបានថាតុលាការដែលចេញសាលក្រម ពិតជាបានស្តាប់ការអះអាងរបស់ភាគីដោយផ្ទាល់ដើម្បីសម្រួលដល់ការស្វែងរកការពិត។

**គ. លក្ខណៈយូរអង្វែង និងស្ថាពរ**

សាលក្រមដែលបានចេញដោយតុលាការ មានអនុវត្តភាពមិនអាចលុប ឬកែប្រែបានឡើយ[13] លើកលែងតែក្នុងករណីមួយចំនួនដែលមានកំណត់នៅក្នុងមាត្រា១៩២នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប្រសិនបើសាលក្រមនោះចូលជាស្ថាពរហើយ វានឹងមានអនុភាពអាជ្ញាអស់ជំនុំ គឺមិនអាចប្តឹងជំទាស់ ឬប្តឹងសើរើបានឡើយ។ មានន័យថា សាលក្រមនោះមានអនុភាពអនុវត្តជារៀងរហូត គ្មានអាជ្ញាយុកាលឡើយ។

**ឃ. លក្ខណៈរឹងមាំ និងរក្សាតុល្យភាពសម្រាប់ភាគី**

ការដោះស្រាយវិវាទតាមផ្លូវតុលាការមានលក្ខណៈរឹងមាំជាគោលការណ៍ច្បាប់ អាចបង្កាមិនអោយមានការគំរាមកំហែង ការសម្លុត ឬបង្កគ្រោះថ្នាក់ដល់ភាគីដែលទន់ខ្សោយ។ មានន័យថា ករណីដែលភាគីវិវាទមានអំណាចមិនស្មើគ្នា (ឧទាហរណ៍ ភាគីម្ខាងជាអ្នកមានឋានៈខ្ពង់ខ្ពស់ ឬមានសេដ្ឋកិច្ចធំ និងភាគីម្នាក់ទៀតជាប្រជាពលរដ្ឋសាមញ្ញ) តុលាការអាចរក្សាតុល្យាភាពក្នុងការដោះស្រាយវិវាទដោយស្មើភាព និងដោយយុត្តិធម៌ទៅតាមគោលការណ៍ និងនីតិវិធីច្បាប់ជាធរមាន។ ករណីបែបនេះ វិសមភាពអាចនឹងកើតមានឡើងសម្រាប់ការដោះស្រាយវិវាទតាមវិធាននៃការចរចា សន្ធានកម្ម ឬមជ្ឈត្តកម្ម ពីព្រោះភាគីម្ខាងមានឥទ្ធិពល និងអំណាចនៃការចរចាខ្ពស់ជាងភាគីម្ខាងទៀត។

**ង. ការធានាមិនឱ្យមានភាពគ្មានហេតុផលរបស់ភាគី**

ក្នុងការដោះស្រាយវិវាទតាមផ្លូវតុលាការ គ្មានភាគីណាមួយអាចធ្វើឥរិយាបថមិនចង់ដោះស្រាយវិវាទដោយគ្មានហេតុផលបានឡើយ។ ភាគីមិនអាចប្រកាន់ជំហរណាមួយដែលមិនសមហេតុផលក្នុងការបដិសេធមិនចូលរួមនៅក្នុងដំណើរការដោះស្រាយវិវាទរបស់តុលាការបានឡើយ ដូចជា ការចូលរួមក្នុងនីតិវិធីសម្រាប់ត្រៀមទាញហេតុផល នីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ ។ល។ មានន័យថា ភាគីត្រូវតែគោរពតាមសេចក្តីបង្គាប់ ឬការស្នើសុំនានារបស់តុលាការ។ ផ្ទុយទៅវិញ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ភាគីអាចលើកហេតុផលនេះ ហេតុផលនោះ ដោយមិនចង់ចរចា ឬក្នុងចេតនាពន្យាពេលដើម្បីគេចវេះពីការប្តឹងទៅតុលាការ ហើយចំពោះសន្ធានការី ឬមជ្ឈត្តករក្តី ក៏មិនអាចធ្វើអ្វីបានឡើយ ព្រោះពួកគេមិនអាចបង្ខំភាគីបានឡើយ ដោយសារការចរចា សន្ធានកម្ម និងមជ្ឈត្តកម្ម គឺជាគោលការណ៍ស្ម័គ្រចិត្ត និងឆន្ទានុសិទ្ធិរបស់ភាគី។

**ច. ការការពារសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋ និងគោលការណ៍មូលដ្ឋាន**

តុលាការរដ្ឋប្បវេណី ដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ដើម្បីការពារសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន។ វិធាននេះ គោរពនូវគោលការណ៍នីត្យានុកូល គោលការណ៍ឯករាជ្យភាពនៃអំណាចតុលាការ គោលការណ៍ចំពោះមុខ គោលការណ៍យុត្តិធម៌ ឆាប់រហ័ស សុចរិត និងស្មោះត្រង់ គោលការណ៍នៃការប្រើប្រាស់ភាសា និងគោលការណ៍នៃការចូលរួមនៃតំណាងអយ្យការ[14]។

---

[13] មាត្រា១៩១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[14] មាត្រា៣, ៤, ៥ និង៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ២. គុណវិបត្តិ

### ក. ការចំណាយខ្ពស់

ការដោះស្រាយវិវាទតាមផ្លូវតុលាការរដ្ឋប្បវេណី ត្រូវការចំណាយថវិកាច្រើនទៅលើការជួលមេធាវី ការបង់ប្រាក់ប្រដាប់ក្ដីលើលិខិតបណ្ដឹង[15] (ឬការបង់ពន្ធសម្រាប់ដាក់ពាក្យ) ការបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ[16] ការបង់ប្រាក់ប្រដាប់ក្ដីភាគី[17] ការចំណាយប្រាក់សម្រាប់ស្វែងរកភស្តុតាង ការចំណាយសម្រាប់ជំនួយការ និងអ្នកបកប្រែ (សម្រាប់ករណីខ្លះដែលភាគីមិនអាចស្ដាប់ ឬអានភាសាខ្មែរបាន) ព្រមទាំងការចំណាយសម្រាប់ការពិន័យផ្សេងៗប្រសិនបើភាគីមិនអនុវត្តតាមសេចក្ដីបង្គាប់របស់តុលាការ ។ល។ និយាយរួម ការដោះស្រាយវិវាទតាមផ្លូវតុលាការ មានការចំណាយខ្ពស់ជាងការចរចា សន្ធានកម្ម និងមជ្ឈត្តកម្ម។ ចំពោះការចរចា គឺមិនចាំបាច់បង់ប្រាក់ប្រដាប់ក្ដី និងការចំណាយផ្សេងៗទៀត ដូចជាការប្ដឹងទៅតុលាការនោះទេ ចំណែកឯសន្ធានកម្ម ជាទូទៅមានរយៈពេលមួយ ឬពីរថ្ងៃ ដូច្នេះថ្លៃសោហ៊ុយមេធាវី និងថ្លៃឈ្នួលមជ្ឈមណ្ឌលសន្ធានកម្មក៏មានតម្លៃថោកតាមនោះដែរ ។ ដោយឡែកមជ្ឈត្តកម្ម ក៏មិនមានការចំណាយច្រើនដូចជាការប្ដឹងទៅតុលាការទេ ដោយសារជាទូទៅមជ្ឈត្តកម្មពុំមានការប្ដឹងឧបាស្រ័យ។

### ខ. ល្បឿននៃការដោះស្រាយយឺត

ការដោះស្រាយវិវាទតាមផ្លូវតុលាការ ជាទូទៅមានល្បឿនយឺតជាងការចរចា សន្ធានកម្ម និងមជ្ឈត្តកម្ម ព្រោះជាធម្មតា គូភាគីត្រូវការពេលវេលាច្រើនដើម្បីរៀបចំរឿងក្ដីរបស់ខ្លួនសម្រាប់ការធ្វើបណ្ដឹងទៅតុលាការ ។ ម្យ៉ាងវិញទៀត តាមរយៈដំណើរការបណ្ដឹងតុលាការ គូភាគីអាចប្ដឹងឧបាស្រ័យយ៉ាងហោចណាស់ម្ដង ហើយជួនកាលច្រើនដងទៀតផង ហេតុនេះហើយក្នុងរឿងក្ដីមួយត្រូវប្រើពេលវេលាច្រើន។ លើសពីនេះទៀត ប្រព័ន្ធតុលាការមានរឿងក្ដីដែលរង់ចាំការដោះស្រាយកកស្ទះយ៉ាងច្រើន ដែលបង្ខំឱ្យគូភាគីរង់ចាំការជំនុំជម្រះយ៉ាងយូរ។ និយាយរួម ការដោះស្រាយវិវាទតាមផ្លូវតុលាការអាចប្រើពេលវេលាជាច្រើនខែ ឬច្រើនឆ្នាំ។

### គ. នីតិវិធីស្មុគស្មាញ

នៅក្នុងបណ្ដឹងតាមផ្លូវតុលាការ ត្រូវប្រើនីតិវិធីស្មុគស្មាញជាច្រើន តាំងពីការចាប់ផ្ដើមបណ្ដឹង (ការដាក់ពាក្យបណ្ដឹង ការទទួលពាក្យបណ្ដឹង) ការជំនុះជម្រះលើបណ្ដឹង (ការត្រៀមសម្រាប់ការទាញហេតុផល ការទាញហេតុផលដោយផ្ទាល់មាត់ ការពិនិត្យភស្តុតាង) រហូតដល់ការបញ្ចប់បណ្ដឹងដោយសាលក្រម ឬដីកាសម្រេចរបស់តុលាការ។ នៅក្នុងដំណាក់កាលនីមួយៗ មាននីតិវិធីលម្អិតជាច្រើនទៀត ដែលជាហេតុធ្វើឱ្យមានការចំណាយពេលវេលាយ៉ាងយូរក្នុងការដោះស្រាយវិវាទតាមផ្លូវតុលាការ។

### ឃ. ភាពមិនអាចរក្សាទំនាក់ទំនងជាបន្ត

នៅក្នុងបណ្ដឹងតាមផ្លូវតុលាការ ដែលមានភាគីទីបីជាអ្នកសម្រេចចំពោះបញ្ហានោះ ការដោះស្រាយអាចមិនជួយឱ្យភាគីទាំងសងខាងសប្បាយចិត្តគ្រប់គ្រាន់ ដើម្បីឱ្យពួកគេបន្តធ្វើការជាមួយគ្នាតទៅទៀតបានឡើយ ពីព្រោះការសម្រេចសេចក្ដីរបស់តុលាការផ្អែកលើគោលការណ៍ច្បាប់ ដោយផ្ដល់លទ្ធផលជាលក្ខណៈ "ឈ្នះ និងចាញ់"។ មានន័យថា ត្រូវតែមានភាគីមួយឈ្នះ និងភាគីម្ខាងទៀតចាញ់ ដែលផ្ទុយពីការដោះស្រាយវិវាទក្រៅ

---

[15] មាត្រា៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[16] មាត្រា៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[17] មាត្រា៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ប្រព័ន្ធតុលាការដែលផ្អែកលើគោលការណ៍ចរចា សម្រុះសម្រួល និងផ្សះផ្សា ដោយតម្រូវឱ្យភាគីព្រមទទួលយកដោយស្ម័គ្រចិត្ត និងដោយឆន្ទានុសិទ្ធិ (គេហៅថា ឈ្នះ-ឈ្នះ)។ នេះមានន័យថា ភាគីទាំងសងខាងឈ្នះទាំងពីរ។

**ង. ការមិនអាចរក្សាភាពជាឯកជន**

ដោយសារការដោះស្រាយវិវាទតាមផ្លូវតុលាការជាទូទៅធ្វើឡើងជាសាធារណៈ ដូចនេះ វាជាគុណវិបត្តិមួយប្រសិនបើវិវាទនោះមានពាក់ព័ន្ធនឹងព័ត៌មានរសើបអំពីភាគី ដែលអាចបណ្តាលឱ្យមានភាពអាម៉ាសនៅពេលផ្សព្វផ្សាយជាសាធារណៈ ឬករណីខ្លះ គូភាគីមិនចង់ឱ្យសាធារណៈជនដឹងអំពីចំណុចលម្អិតនៃវិវាទរបស់ខ្លួន។ ហេតុនេះ ការដោះស្រាយវិវាទជាសាធារណៈតាមនីតិវិធីរបស់តុលាការ មិនអាចរក្សាភាពជាឯកជន ឬព័ត៌មានរសើបរបស់គូភាគីបានឡើយ។ ផ្ទុយទៅវិញ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មានដំណើរការជាឯកជន និងតម្រូវឱ្យមានការរក្សាការសម្ងាត់[18] (ករណីសន្ទានកម្ម និងមជ្ឈត្តកម្ម)។ ចំពោះការចរចាវិញ គឺមានដំណើរការជាឯកជនទាំងស្រុងដោយគ្រាន់តែធ្វើឡើងរវាងភាគី និងភាគី ឬតំណាងរបស់ពួកគេតែប៉ុណ្ណោះ ដោយគ្មានការចូលរួមពីតុលាការ គ្មានអ្នកសារព័ត៌មាន និងគ្មានអ្នកដទៃទៀតចូលរួមទេ។ សូម្បីតែមេធាវីក៏ភាគីវិវាទមិនចាំបាច់អញ្ជើញឱ្យចូលរួមដែរ ហើយទោះបីជាមានវត្តមានមេធាវីចូលរួមក្តី ក៏សេចក្តីលម្អិតនៃវិវាទនឹងនៅតែជាលក្ខណៈឯកជនដដែល ព្រោះមេធាវីត្រូវតែរក្សាការសម្ងាត់ជាដាច់ខាតចំពោះទំនាក់ទំនងជាមួយកូនក្តីរបស់ខ្លួន[19]។

ប្រការនេះ (សំដៅលើការរក្សាភាពជាឯកជន) អាចមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់មនុស្ស និងអាជីវកម្ម ពីព្រោះប្រសិនបើព័ត៌មានជាឯកជនមួយចំនួនមិនត្រូវបានរក្សា នោះវាអាចនឹងបណ្តាលឱ្យប៉ះពាល់ដល់មុខមាត់ កេរ្តិ៍ឈ្មោះ និងការប្រកបរបរអាជីវកម្មផ្សេងៗរបស់ភាគី ។

**ច. ភាពរឹងត្អឹង មិនអាចបត់បែនបាន**

ការដោះស្រាយវិវាទតាមផ្លូវតុលាការ គឺចៅក្រមដោះស្រាយដោយផ្អែកលើច្បាប់ជាធរមាន ដែលជាការរិតត្បិតផ្នែកគំនិតច្នៃប្រឌិត និងភាពបត់បែន។ មានន័យថា ភាគវិវាទមិនមានលទ្ធភាពបត់បែនក្នុងការរៀបចំដំណើរការដោះស្រាយវិវាទរបស់ខ្លួន ដូចជាការចរចា និងសន្ទានកម្មឡើយ គឺត្រូវតែគោរពតាមនីតិវិធីច្បាប់។

**ឆ. ការបាត់បង់លទ្ធភាពនៃការគ្រប់គ្រងរបស់ភាគី**

ការដោះស្រាយវិវាទតាមផ្លូវតុលាការ គឺភាគីមិនអាចគ្រប់គ្រងលើលទ្ធផលរបស់ខ្លួនបានទេ ពីព្រោះការសម្រេចសេចក្តីក្នុងការដោះស្រាយវិវាទដែលជាលទ្ធផលចុងក្រោយនៃវិវាទនោះ ស្ថិតនៅលើតុលាការទាំងស្រុង។ មានន័យថា ភាគីវិវាទមិនអាចសម្រេចថាតើនឹងដោះស្រាយដែរឬទេ និងនៅក្នុងលក្ខខណ្ឌអ្វីខ្លះ ហើយពួកគេមិនអាចកំណត់ដំណើរការដោះស្រាយវិវាទដោយខ្លួនឯងឡើយ។

## ៣. សន្និដ្ឋាន

ទាញចេញពីគុណសម្បត្តិ និងគុណវិបត្តិខាងលើនេះ យើងអាចសន្និដ្ឋានបានថា នៅពេលដែលវិវាទរដ្ឋប្បវេណីកើតឡើង ហើយភាគីវិវាទចង់បានដំណើរការមួយដែលមានលក្ខណៈផ្លូវការ ស្ថាពរ យូរអង្វែង តឹងរឹងជាសាធារណៈ និងដោយមិនសូវខ្វល់អំពីពេលវេលា ភាពបត់បែន ទំនាក់ទំនងជាមួយភាគីម្ខាងទៀត ជាដើម ភាគីគួរជ្រើសរើសវិធាននៃការដោះស្រាយវិវាទតាមផ្លូវតុលាការរដ្ឋប្បវេណី។ ប៉ុន្តែ ប្រសិនបើភាគីមានគោលបំណងផ្ទុយពីខាងលើនេះវិញ ភាគីគួរជ្រើសរើសយកវិធាននៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

---

[18] លក្ខខណ្ឌនេះតម្រូវចំពោះអ្នកតំណាង មេធាវី និងភាគីទីបី។ មានន័យថា មនុស្សទាំងបីនាក់នេះ ត្រូវតែរក្សាការសម្ងាត់ឱ្យភាគី។

[19] ច្បាប់ស្តីពីសហលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៥) មាត្រា៥៨ និងក្រមសីលធម៌សម្រាប់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៧។